# ប្រវត្តិការណ៍នៃការផ្លាស់ប្តូររដ្ឋធម្មនុញ្ញ
# នៅប្រទេសកម្ពុជា

**បណ្ឌិត ឆេង វណ្ណារិទ្ធ**
**ប្រធានស្តីទីវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម**

## មូលន័យសង្ខេប

ក្នុងអត្ថបទស្តីពី "ប្រវត្តិការណ៍នៃការផ្លាស់ប្តូររដ្ឋធម្មនុញ្ញនៅប្រទេសកម្ពុជា" អ្នកនិពន្ធមានបំណងលើកយកចំណុចសំខាន់ៗនៃខ្លឹមសារមានចែងក្នុងរដ្ឋធម្មនុញ្ញ ដែលក្នុងរយៈពេលត្រឹមតែ៥០ឆ្នាំប៉ុណ្ណោះ(ឆ្នាំ១៩៥៣ ដល់ ឆ្នាំ១៩៩៣)ត្រូវបានផ្លាស់ប្តូរចំនួនប្រាំដង ទាំងឈ្មោះប្រទេស ទង់ជាតិ ភ្លេងជាតិ រដ្ឋធម្មនុញ្ញ របៀបរបបគ្រប់គ្រងរដ្ឋ នយោបាយ សេដ្ឋកិច្ចសង្គម និងទាំងផ្នត់គំនិតដល់ឫសគល់ ហើយជាលទ្ធផលចុងក្រោយនៃការផ្លាស់ប្តូរទាំងអស់នេះ ធ្វើឱ្យប្រជាពលរដ្ឋស្ទើរវិនាសអស់ និងប្រទេសជាតិស្ទើរតែធ្លាក់ក្នុងក្តីអន្តរាយ បាត់បង់កិត្តិយស និងកិត្យានុភាពដែលធ្លាប់មានក្នុងសម័យមហានគរ។ តាមរបាយការណ៍របស់មូលនិធិរូបិយវត្ថុអន្តរជាតិ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩ បានឱ្យដឹងថា ផលិតផលក្នុងស្រុកតែនាមសម្រាប់មនុស្សម្នាក់(GDP per capita(nominal)) របស់ប្រទេសកម្ពុជាសម្រាប់ឆ្នាំ២០១៨ គឺមានចំនួន ១ ៤៨៥ ដុល្លារអាម៉េរិក ដែលស្ថិតក្នុងលំដាប់ថ្នាក់ទី៩ ក្នុងចំណោមបណ្តាប្រទេសទាំង១០នៃសមាជិកអាស៊ាន និងលំដាប់ថ្នាក់ទី១៥៥ នៅលំដាប់ទូទាំងពិភពលោក[1]។

នៅថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣ មានពិធីចុះហត្ថលេខាបារាំង-កម្ពុជាស្តីអំពីអាណាព្យាបាលបារាំង។ ថ្ងៃទី១៧ ខែតុលា ឆ្នាំ១៨៨៧ បារាំងបានចេញសេចក្តីប្រកាស បង្កើតសហភាពឥណ្ឌូចិន ក្នុងគោលបំណងបង្រួបបង្រួមប្រទេសកម្ពុជា ជាមួយនឹងដែនដីអាណានិគមរបស់ខ្លួនដទៃទៀតនៅឥណ្ឌូចិន តាមរយៈនៃប្រព័ន្ធសហភាពឥណ្ឌូចិន។ នៅថ្ងៃទី៣ ខែសីហា ឆ្នាំ១៨៩០ រដ្ឋការបារាំងបានទិញសិទ្ធិផ្តាច់មុខនូវសិទ្ធិក្នុងការយកពន្ធអាករលើអង្ករនាំចេញពីប្រទេសកម្ពុជា ហើយចាប់ពីឆ្នាំ១៨៩១ ពន្ធអាករត្រូវដាក់ឱ្យនៅក្រោមការត្រួតពិនិត្យរបស់រដ្ឋការបារាំងទាំងអស់។ នៅថ្ងៃទី១ ខែមករា ឆ្នាំ១៨៩២ គេបានបង្កើតក្រសួងហិរញ្ញវត្ថុដែលស្ថិតនៅក្រោមការត្រួតពិនិត្យរបស់បារាំង។ ក្នុងឆ្នាំ១៩០០ នៅប្រទេសកម្ពុជា ជនជាតិអឺរ៉ុបមានដីចម្ការធំៗទាំងអស់ចំនួន១៥កន្លែង ដែលមានទំហំ២៣៥ហិកតា។ នេះគឺជាការសាកល្បងលើកទីមួយ ក្នុងការបង្កើតកសិដ្ឋានដំណាំតាមរបៀបមូលធននិយម ជាពិសេស កសិដ្ឋានសម្រាប់ដំណាំស្រូវ។ រហូតមកដល់សម័យសង្គ្រាមលោកលើកទីមួយ(ខែកក្កដា ឆ្នាំ១៩១៤)មូលធនហិរញ្ញវត្ថុបារាំងបានបង្កើតលក្ខខណ្ឌដ៏ចាំបាច់ ដើម្បីទាក់ទាញដើមទុនឯកជនបារាំងឱ្យចូលហ៊ុនក្នុងវិស័យសំខាន់ៗនៃសេដ្ឋកិច្ចប្រទេសកម្ពុជា។ ជីវភាពខាងសេដ្ឋកិច្ចទាំងមូលនៃប្រទេស

[1] Source: International Monetary Fund World Economic Outlook(October-2018), Date 20 Mar 2019.

នៅឥណ្ឌូចិន រួមទាំងប្រទេសកម្ពុជាផងត្រូវបានស្ថិតនៅក្រោមការគ្រប់គ្រងរបស់ធនាគារ "ឥណ្ឌូចិន" ។ នៅមុនសម័យសង្គ្រាមលោកលើកទីពីរ(ខែកញ្ញា ឆ្នាំ១៩៣៩)ប្រទេសនានានៅឥណ្ឌូចិនបានប្រែក្លាយទៅជាប្រទេសផលិតករនូវផលិតផលកសិកម្ម និងវត្ថុធាតុដើមសម្រាប់ប្រទេសបារាំង។ ការកកើតនៃទំនាក់ទំនងតាមបែបមូលធននិយម និងការបង្កើតរបបអាណានិគមនៃអំពើជិះជាន់លើប្រទេសកម្ពុជាបានផ្តល់ឥទ្ធិពលជាអវិជ្ជមាន ជាពិសេស ទៅលើស្ថានភាពកសិករ។ កសិករក្រីក្របានក្លាយទៅជាអ្នកជាប់បំណុលនឹងឈ្មួញកណ្តាល ឬ ឈ្មួញឯកជនកាន់តែច្រើនឡើងៗ ជាពិសេស ជនជាតិចិន បារាំង ឥណ្ឌា វៀតណាម ដែលរស់នៅស្រុកស្រែចម្ការ ក៏ដូចជានៅទីក្រុង។ នៅឆ្នាំ១៩២៦ រដ្ឋបាលអាណានិគមបារាំង បានបង្កើតច្បាប់មួយដែលបញ្ជាក់ថា"បុគ្គលដែលមិនមែនជាពលរដ្ឋបារាំង ឬ ដែលមិនមែនស្ថិតនៅក្នុង "ក្រុមបុគ្គលប្រកបដោយបុព្វសិទ្ធិ" ត្រូវបានហាមឃាត់មិនឱ្យមានកម្មសិទ្ធិលើដីនៅប្រទេសកម្ពុជា"។ ដោយយោងទៅតាមច្បាប់នេះ ចាប់ពីពេលនោះមករដ្ឋការអាណានិគមបានបែងចែកឡូត៍ដីធំៗដល់ពលរដ្ឋបារាំង ជាពិសេស ដល់ក្រុមហ៊ុនផ្តាច់មុខសម្រាប់ដាំដំណាំស្រូវ កាហ្វេ ម្រេច និងកៅស៊ូ។ ពលរដ្ឋបារាំងបានទទួលដីសម្បទាន ដែលមានទំហំដល់៧០ភាគរយ ចំណែកនៅសល់ ៣០ភាគរយ ត្រូវបានបែងចែកដល់អភិជន។ ដីសម្បទានមួយចំនួនធំជិត៥០ភាគរយ បានត្រូវប្រើប្រាស់ដើម្បីដំណាំកៅស៊ូ។ ជាមួយគ្នានឹងការប្រើប្រាស់ដើមទុនបារាំង នៅក្នុងសេដ្ឋកិច្ចប្រទេសកម្ពុជាគឺមានការចូលហ៊ុនពីសំណាក់ដើមទុននិងឈ្មួញកណ្តាលរបស់ជនជាតិចិន និងវៀតណាម។ ក្រុមហ៊ុនជំនួញរបស់ជនជាតិចិន និងវៀតណាម បានដើរតួនាទីជាឈ្មួញកណ្តាល រវាងក្រុមហ៊ុនផ្តាច់មុខបារាំង និងផ្សារនានា នៅក្នុងប្រទេសទាំងឡាយនៃសហភាពឥណ្ឌូចិន[2]។

នៅប្រទេសកម្ពុជាមានរដ្ឋធម្មនុញ្ញ ហើយត្រូវបានផ្លាស់ប្តូរជាច្រើនដង។

១- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាទី១ (១៩៤៧-១៩៧០)

មាត្រា១ ៖ ប្រទេសកម្ពុជា ជាប្រជាជាតិមួយ មានព្រះមហាក្សត្រសោយរាជ្យ។

មាត្រា២៥៖ រាជសម្បត្តិប្រទេសកម្ពុជា ជារបស់ក្សត្រាទាំងឡាយ ដែលជាតំណពីព្រះបាទសម្តេចព្រះហរិរក្សរាមាធិបតី ព្រះអង្គឌួង។

ថ្ងៃទី៦ ខែឧសភា ឆ្នាំ១៩៤៧ រដ្ឋធម្មនុញ្ញលើកទី១របស់ប្រទេសកម្ពុជាត្រូវបានប្រកាសឱ្យប្រើប្រាស់។ នៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ បារាំងបានប្រគល់ឯករាជ្យភាពមកខ្មែរវិញ។ នៅខែកញ្ញា ឆ្នាំ ១៩៥៥ តំណាងរាស្ត្រនៅរដ្ឋសភាកម្ពុជាបានអនុម័តិលើសេចក្តីសម្រេចចិត្តស្តីអំពី ការដកថយប្រទេសកម្ពុជាចេញពីសហភាពបារាំង ហើយបានរំលាយប្រព័ន្ធរដ្ឋការគយ រវាងប្រទេសបារាំងនិងរដ្ឋ ចូលរួមក្នុងសហភាពបារាំងនៅឥណ្ឌូចិន នាខែធ្នូ ឆ្នាំ១៩៥៤ ដែលបានផ្តល់លទ្ធភាពឱ្យរដ្ឋាភិបាលកម្ពុជាអាចធ្វើការត្រួតត្រាលើប្រព័ន្ធរូបិយបណ្ណនិងរដ្ឋការគយរបស់ប្រទេស ហើយអាចដកខ្លួនថយចេញពីឥទ្ធិពលនៃតំបន់ប្រាក់ហ្វ្រង់។ នៅពេលនោះ ប្រទេសកម្ពុជាចាប់ផ្តើមបង្កើតធនាគារជាតិ និង ការបោះពុម្ពឱ្យប្រើប្រាស់ប្រាក់ថ្មីជាលុយរៀល។ ក្រោយទទួលបានឯករាជ្យ ការលូតលាស់សេដ្ឋកិច្ចប្រទេសជាតិ គឺពឹងផ្អែកលើវិស័យមូលធនរបស់រដ្ឋ មូលធនឯកជនរបស់ជាតិ និងមូលធនចម្រុះ។ ការបង្កើតវិស័យ

[2] សូមមើល : ឆេង វណ្ណារិទ្ធ "សេដ្ឋកិច្ចអន្តរកាលៈ បទពិសោធន៍ប្រទេសមួយចំនួន", ភ្នំពេញ, រាជបណ្ឌិត្យសភាកម្ពុជា, ខែសីហា ឆ្នាំ២០១៥, ទំព័រ១-១៤។

របស់រដ្ឋត្រូវបានធ្វើឡើងតាមបីមុខសញ្ញា : ប្រមូលទិញទ្រព្យមូលធនរបស់ក្រុមហ៊ុនបរទេស សាងសង់រោងចក្រថ្មី និងពង្រីកភាគហ៊ុនក្នុងក្រុមហ៊ុនចម្រុះ។ ចំពោះមុខងារខាងពាណិជ្ជកម្ម តាមស្ថិតិនាឆ្នាំ ១៩៦២ មូលធនបារាំងបានកាន់កាប់ស្ថានភាព១/៣ នៃក្រុមហ៊ុនពាណិជ្ជនាំចេញទាំងអស់នៅក្នុងកម្ពុជា ហើយមូលធនបារាំងបានស្ថិតនៅជាមូលធនដ៏សំខាន់នៅក្នុងវិស័យសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា រីឯ មុខងារខាងពាណិជ្ជកម្មអាហារណែនីហរណែដែលបានបំពេញដោយក្រុមហ៊ុនបរទេសត្រូវបានប្រគល់ដល់ក្រុមហ៊ុនថ្មីរបស់ខ្មែរ។ នៅសម័យកាលនៃឆ្នាំ១៩៦០ គេសង្កេតឃើញសភាពការណ៍នៃការកកើតវណ្ណៈ នៅស្រុកស្រែ និងមានភាពក្រីក្រកាន់តែខ្លាំងឡើង។ ចាប់ពីខែសីហា ឆ្នាំ១៩៦៩ រដ្ឋាភិបាលបានបញ្ឈប់ធ្វើជាតូបនីយកម្ម និងកែប្រែវិស័យសេដ្ឋកិច្ចរបស់ប្រទេសឱ្យទៅជាកម្មសិទ្ធិរបស់ឯកជន។

២- រដ្ឋធម្មនុញ្ញសាធារណៈរដ្ឋខ្មែរ (១៩៧០-១៩៧៥)

មាត្រា១ ៖ ប្រទេសកម្ពុជាមាននាមថា "សាធារណរដ្ឋខ្មែរ" ។

មាត្រា១៤ ៖ រដ្ឋទទួលស្គាល់ហើយធានាអះអាងនូវកម្មសិទ្ធិឯកជន។ រដ្ឋជួយសម្រួលឱ្យពលរដ្ឋបានជាម្ចាស់កម្មសិទ្ធិ។ ការប៉ះពាល់កម្មសិទ្ធិត្រូវហាម វៀរលែងតែប្រយោជន៍សាធារណៈតម្រូវឱ្យធ្វើ ក្នុងករណីដែលមានចែងក្នុងច្បាប់។ ក្នុងន័យនេះ ម្ចាស់កម្មសិទ្ធិទទួលប្រាក់សំណងជាមុន ដោយត្រឹមត្រូវ និង សមរម្យ។

នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ក្រុមប្រឹក្សារាជាណាចក្រ និង រដ្ឋសភាជាតិ បានធ្វើសេចក្តីសម្រេចប្រកាស ស្តីអំពីការរំលំសម្តេច នរោត្តម សីហនុ។ នៅថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧០ គេបានប្រកាសការបង្កើត "សាធារណរដ្ឋខ្មែរ" ហើយលោក លន់ នល់ ត្រូវបានក្លាយជា ប្រធានាធិបតី។ នាថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៧២ រដ្ឋធម្មនុញ្ញថ្មីត្រូវ បានប្រកាសឱ្យប្រើប្រាស់ជំនួសរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧។ នៅក្នុងរបបសាធារណរដ្ឋខ្មែរ(ដែលមានរយៈពេល៥ឆ្នាំ ១ខែ) សង្គ្រាមស៊ីវិលបាន រីករាលដាលពេញទូទាំងប្រទេស បណ្តាលឱ្យជនជាតិខ្មែរប្រមាណជាង១លាននាក់(ប្រមាណជា១/៧នៃប្រជាជនកម្ពុជា) ស្លាប់ របួស និង ក្លាយជាជនពិការ និង មានជនភៀសខ្លួនរាប់សែននាក់រត់ចោលលំនៅស្ថាន។ ជាមួយគ្នានេះដែរ រោងឧស្សាហកម្ម៤/៥ ត្រូវបានបំផ្លិចបំផ្លាញ ចំការកៅស៊ូ ២/៣ បានត្រូវបាត់បង់ ផ្លូវថ្នល់និងផ្លូវដែក៧០-៨០%បានត្រូវខូចខាត កំពង់ផែនិងកំពង់ចម្លងបានទទួលខូចខាតយ៉ាងធ្ងន់ធ្ងរ។ ផលិតកម្មផ្នែកកសិកម្មបានធ្លាក់ចុះ១/៤ ចំណែកឯ វិស័យឧស្សាហកម្មបានធ្លាក់ចុះដល់១/៨ បើប្រៀបធៀបមុនឆ្នាំ១៩៧០។ ប្រទេសកម្ពុជាដែលជាប្រទេសនាំអង្ករទៅលក់នៅក្រៅប្រទេស បានក្លាយជាប្រទេសដែលនាំអង្ករចូលពីប្រទេសក្រៅវិញ។ ទំនិញចាំបាច់សម្រាប់ជីវភាពរស់នៅឡើងថ្លៃហួសកម្រិត ភាពអត់ការងារធ្វើមានកាន់តែច្រើនឡើងៗ ជីវិតរស់នៅសម្រាប់ប្រទេសកម្ពុជា គឺអាស្រ័យពីជំនួយរបស់បរទេសទាំងស្រុង។

៣- រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៨)

មាត្រា១ ៖ រដ្ឋកម្ពុជា ជារដ្ឋរបស់ប្រជាជន កម្មករ កសិករ និង ពលករ កម្ពុជាផ្សេងទៀតទាំងអស់។ រដ្ឋកម្ពុជាមានឈ្មោះជាផ្លូវការថា "កម្ពុជា ប្រជាធិបតេយ្យ" ។

មាត្រា២ ៖ មធ្យោបាយផលិតកម្មសំខាន់ៗជាទូទៅ ជាកម្មសិទ្ធិរបស់ប្រជាជន និង កម្មសិទ្ធិរួមរបស់ប្រជាជនសមូហភាព រីឯ របស់របរប្រើប្រាស់ប្រចាំថ្ងៃស្ថិតនៅជាកម្មសិទ្ធិរបស់ឯកជន។

មាត្រា៣ ៖ កម្ពុជាប្រជាធិបតេយ្យអនុវត្តរបបសមូហភាពក្នុងការដឹកនាំ និង ធ្វើការងារ។

មាត្រា១២ ៖ ប្រជាជនកម្ពុជាគ្រប់រូបមានសិទ្ធិជីវភាពពេញទីខាងសម្ភារៈ ខាងស្មារតី និង ខាងវប្បធម៌ ដែលត្រូវបានកែប្រែឱ្យរីកចម្រើនកាន់តែខ្ពស់ឡើងជានិច្ច។ ប្រជាជនកម្ពុជាគ្រប់រូបសុទ្ធតែត្រូវបានធានាអះអាងខាងជីវភាពទាំងអស់។

- កម្មករគ្រប់រូបជាម្ចាស់រោងចក្រ។
- កសិករគ្រប់រូបជាម្ចាស់ស្រែចម្ការ។
- ពលករផ្សេងទៀតមានសិទ្ធិមានការងារធ្វើទាំងអស់គ្នា។
- ភាពគ្មានការងារធ្វើមិនមានដាច់ខាតក្នុងកម្ពុជាប្រជាធិបតេយ្យ។

ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ របប "សាធារណរដ្ឋខ្មែរ" ត្រូវបានដួលរលំ។ រដ្ឋធម្មនុញ្ញថ្មីមួយទៀតត្រូវបានបង្កើតឡើងនៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៦ ជំនួសរដ្ឋធម្មនុញ្ញឆ្នាំ១៩៧២ ហើយប្រទេសកម្ពុជា ត្រូវបានគេឱ្យឈ្មោះថា "កម្ពុជាប្រជាធិបតេយ្យ"។ នយោបាយ សេដ្ឋកិច្ចនៃរបបនេះគឺមនោគមវិជ្ជាបដិបក្ខភាព រវាងប្រជាកសិករនិងវណ្ណៈពាណិជ្ជករចងការប្រាក់។ គេចាត់ទុកទីក្រុងគឺជាប្រភពនៃមូលធននិយមដែលជាមធ្យោបាយបង្កើតអំពើជិះជាន់វណ្ណៈកសិករ ហើយដើម្បីបំបាត់អំពើជិះជាន់ គេបានបំបាត់ការប្រើប្រាស់លុយក្នុងសេដ្ឋកិច្ច តែគេបានបង្កើតនូវសហករណ៍គ្រប់ទីកន្លែងនៅទូទាំងប្រទេស។ ចំពោះបញ្ហាឧស្សាហូបនីយកម្ម "ពឹងផ្អែកលើកម្លាំងផ្ទាល់ខ្លួន" ដែលជាលក្ខណៈសេដ្ឋកិច្ចបិទ(Closed Economy) ផ្តាច់ទំនាក់ទំនងជាមួយពិភពខាងក្រៅ ដូចជា វិស័យពាណិជ្ជកម្ម និង កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចជាដើម។ របបនេះបានបណ្តេញប្រជាពលរដ្ឋទាំងអស់ ចេញពីទីក្រុងភ្នំពេញ ទីប្រជុំជនធំៗ ឱ្យទៅនៅតាមជនបទ និងនៅតាមវាលរហោស្ថាន ដើម្បីធ្វើកសិកម្ម។ ប្រជាជនទាំងអស់នៅក្នុងប្រទេសបានត្រូវបែងចែកជាបីប្រភេទ គឺ "ប្រជាជនចាស់" "ប្រជាជនថ្មី" និង "អតីតមន្ត្រីរាជការរបបមុន"។ ក្នុងរបបនេះគ្មានអ្វីជាទ្រព្យសម្បត្តិកម្មសិទ្ធិឯកជនបន្តិចឡើយ។ ជាមួយនឹងការបំបាត់ទ្រព្យសម្បត្តិឯកជន គឺមានទាំងការបំបាត់ទ្រព្យផ្ទាល់ខ្លួន ចាប់ពីចាន ឆ្នាំងទៅ។ ការសម្លាប់ដោយចំហ និងដោយប្រយោល ដូចជា ធ្វើការងារយ៉ាងធ្ងន់ធ្ងរ បង្អត់អាហារ គ្មានថ្នាំសង្កូវព្យាបាលពេលមានជំងឺ ហើយធ្វើឱ្យប្រជាជនកម្ពុជាស្លាប់អស់ប្រមាណជា ១លាន ២សែន នាក់ ដែលក្នុងនោះមានទាំងមនុស្សចាស់ បុរស នារី និង កុមារ(គិតពីខែមេសា ឆ្នាំ១៩៧៥ ដល់ខែធ្នូ ឆ្នាំ១៩៧៦)ហើយប្រជាពលរដ្ឋដែលមានជីវិតប្រមាណជា៨០% មានជំងឺគ្រុនចាញ់ និងបាត់បង់សមត្ថភាពក្នុងការបំពេញពលកម្ម(សូមមើល : ឡុង សៀម "ប្រវត្តិសាស្ត្រសង្ខេបនៃប្រទេសកម្ពុជា", បណ្ឌិតសភាវិទ្យាសាស្ត្រ ស.ស.ស. ស.វិទ្យាស្ថាននៃបូព៌ាសាស្ត្រ, ទំព័រ៥០៦)[3] ។

៤-រដ្ឋធម្មនុញ្ញសាធារណរដ្ឋប្រជាមានិតកម្ពុជា(១៩៨១-១៩៨៦)

មាត្រា១ ៖ ប្រទេសកម្ពុជាមាននាមជាផ្លូវការថា "សាធារណរដ្ឋប្រជាមានិតកម្ពុជា" ។

មាត្រា១១ ៖ សេដ្ឋកិច្ចជាតិស្ថិតនៅក្រោមការដឹកនាំរបស់រដ្ឋ។

---

[3] សូមមើល : ឡុង សៀម "ប្រវត្តិសាស្ត្រសង្ខេបនៃប្រទេសកម្ពុជា", បណ្ឌិតសភាវិទ្យាសាស្ត្រ ស.ស.ស. ស. វិទ្យាស្ថាននៃបូព៌ាសាស្ត្រ, ទំព័រ ៥០៦

មាត្រា១២ ៖ សេដ្ឋកិច្ចជាតិមានបីផ្នែក : សេដ្ឋកិច្ចរដ្ឋ សេដ្ឋកិច្ច សមូហភាព និង សេដ្ឋកិច្ចគ្រួសារ។ រដ្ឋគ្រប់គ្រងសហគ្រាសរដ្ឋយ៉ាងជិតដិតដើម្បីពង្រីកតួនាទីសំខាន់នៃផ្នែកសេដ្ឋកិច្ចរដ្ឋក្នុងសេដ្ឋកិច្ចជាតិ ហើយទន្ទឹមនឹងនោះជួយទំនុកបម្រុង ព្រមទាំងណែនាំយ៉ាងសកម្មនូវការកសាងសេដ្ឋកិច្ចសមូហភាព និង សេដ្ឋកិច្ចគ្រួសារឱ្យរីកចម្រើនតាមទិសដែលមានប្រយោជន៍ដល់រដ្ឋ និង ជីវភាពរស់នៅរបស់ប្រជាជន។

មាត្រា១៣ ៖ រដ្ឋយកចិត្តទុកដាក់ពង្រីកផលិកម្មឧស្សាហកម្មដែលបម្រើកសិកម្ម ពង្រីកផលិតផលដែលប្រើប្រាស់ ពង្រីកពាណិជ្ជកម្ម គមនាគមន៍និងដឹកជញ្ជូន។ រដ្ឋជួយទំនុកបម្រុងនិងពង្រីកសិប្បកម្មនិងឧស្សាហកម្ម។

មាត្រា១៤ ៖ ទ្រព្យសម្បត្តិជាកម្មសិទ្ធិរបស់រដ្ឋ មាន ដីធ្លី ព្រៃឈើ សមុទ្រ ទន្លេ បឹង ធនធានធម្មជាតិ មជ្ឈមណ្ឌលសេដ្ឋកិច្ច វប្បធម៌ មូល ដ្ឋានការពារប្រទេស និង សំណង់ផ្សេងៗទៀតរបស់រដ្ឋ។

មាត្រា ១៧ ៖ ជនណាក៏ដោយគ្មានសិទ្ធិទិញ លក់ បញ្ចាំ ឬ ប្រវាស់ដីធ្លីបានឡើយ។ ជនណាក៏ដោយមិនអាចប្រើប្រាស់ដីធ្លី កសិកម្ម ដីព្រៃ ដោយចិត្តឯងក្នុងគោលបំណងផ្សេងទៀត បើគ្មានការអនុញ្ញាតពីក្រសួងមានសមត្ថកិច្ច។

មាត្រា ១៩ ៖ ពាណិជ្ជកម្មក្រៅប្រទេសស្ថិតនៅក្រោមការគ្រប់គ្រងផ្តាច់មុខរបស់រដ្ឋ។

ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ "របបកម្ពុជាប្រជាធិបតេយ្យ" ត្រូវបានផ្តួលរំលំ។ នាថ្ងៃទី១០ ខែមករា ឆ្នាំ១៩៧៩ ប្រទេសកម្ពុជាត្រូវបានប្រកាសជា "សាធារណរដ្ឋប្រជាមានិតកម្ពុជា"។

នៅក្នុងសម័យប្រជុំនីតិកាលទី១នៃរដ្ឋសភា ដែលបានដំណើរការ ពីថ្ងៃទី២៤ ដល់២៧ ខែមិថុនា ឆ្នាំ១៩៨១ គេបានអនុម័តរដ្ឋធម្មនុញ្ញថ្មី ជំនួសរដ្ឋធម្មនុញ្ញឆ្នាំ១៩៧៦។ រដ្ឋាភិបាលបានធ្វើការអំពាវនាវដល់បណ្តាកសិករឱ្យបង្កើត "ក្រុមសាមគ្គីបង្កបង្កើនផល"។ អំឡុងឆ្នាំ១៩៧៩-១៩៨០ នៅប្រទេសកម្ពុជាបានបង្កើត "ក្រុមសាមគ្គីបង្កបង្កើនផល" ចំនួន៧០ពាន់ក្រុម ដែលក្នុងមួយក្រុមៗ មានចំនួនពី១៥ទៅ២០គ្រួសារ។ កសិករទូទាំងប្រទេសចំនួន៩០% បានបង្កើតជា "ក្រុម សាមគ្គីបង្កបង្កើនផល"។ រហូតដល់ខែមីនា-មេសា ឆ្នាំ១៩៨០ បានចាប់ផ្តើមប្រើប្រាស់ប្រាក់រៀលរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា។ ក្នុងសម័យប្រជុំមហាសន្និបាតទី៤របស់បក្សកុម្មុយនីស្តកម្ពុជា ដែលបានប្រព្រឹត្តទៅពីថ្ងៃទី២៦-២៩ ខែឧសភា ឆ្នាំ១៩៨១ គេបានអនុម័តអំពីដំណើរឈានឡើងទៅកាន់សង្គមនិយម ហើយសេដ្ឋកិច្ចប្រទេសកម្ពុជានឹងបង្រួមវិស័យសេដ្ឋកិច្ចបីប្រភេទ គឺសេដ្ឋកិច្ចរដ្ឋដែលនៅក្នុងនោះ មានរោងឧស្សាហកម្មទាំងអស់ គមនាគមន៍ សហគ្រាសសេដ្ឋកិច្ច និង ពាណិជ្ជកម្មមួយចំនួនធំ, សេដ្ឋកិច្ចសមូហភាពដែលនៅក្នុងនោះមានក្រុមសាមគ្គីបង្កបង្កើនផលទាំងឡាយ, សេដ្ឋកិច្ចគ្រួសារដែលនៅក្នុងនោះមានកសិករឯកជន អ្នកលក់ដូរតូចតាច សិប្បករឯកជន តែរដ្ឋយកចិត្តទុកដាក់ជាពិសេស ដល់ការពង្រីកសេដ្ឋកិច្ចរដ្ឋ, និង សេដ្ឋកិច្ចសមូហភាព។

នៅក្នុងសៀវភៅ " ហ៊ុន សែន ៖ ១០ឆ្នាំនៃដំណើរកម្ពុជា ១៩៧៩-១៩៨៩"[4] ទំព័រ២៣០ បានសរសេរថា ៖ "ប៉ុន្មានខែដំបូងនេះ ប្រហែលជា៨០% នៃចំនួនប្រជាពលរដ្ឋគ្មានបានបង្កបង្កើនផលអ្វី

---

[4] សូមមើល : ហ៊ុន សែន ៖ ១០ឆ្នាំនៃដំណើរកម្ពុជា ១៩៧៩-១៩៨៩"ទំព័រ២៣០

ទេ˝ ក្នុងទំព័រ ២៣៦ ៖ ˝ ... យើងអាចកសាងសេដ្ឋកិច្ចសង្គមនិយមតែម្តងដោយអនុញ្ញាតឱ្យមានតែសមាសភាពសេដ្ឋកិច្ចរដ្ឋនិងសេដ្ឋកិច្ចសមូហភាពបានហើយ រីឯ សេដ្ឋកិច្ចគ្រួសារ គឺស្ថិតក្នុងសមាសភាពបន្ទាប់បន្សំតូចតាចតែប៉ុណ្ណោះ ហើយមិនចាំបាច់ឱ្យមានសេដ្ឋកិច្ចឯកជនទេ ព្រោះសមាសភាពសេដ្ឋកិច្ចឯកជន បានស្លាប់តាំងពីក្នុងរបប ប៉ុល ពត ទៅហើយ មិនត្រូវឱ្យវារស់ឡើងវិញទេ˝។ រហូតដល់ចុងឆ្នាំ១៩៨៤ ក្នុងឱកាសសន្និបាតកម្មាភិបាលទូទាំងប្រទេសរបស់បក្ស នាថ្ងៃទី២ ដល់ថ្ងៃ ទី៩ ខែវិច្ឆិកា ឆ្នាំ១៩៨៤ ទើបឱ្យសច្ចាប័នទទួលស្គាល់សមាសភាព សេដ្ឋកិច្ចឯកជន ហើយរដ្ឋសភាក៏បានបញ្ចូលទៅក្នុងរដ្ឋធម្មនុញ្ញ ក្នុងសម័យប្រជុំលើកទី១០ នីតិកាលទី១ នាថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ១៩៨៦។

៥- រដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា(១៩៨៩-១៩៩៣)

មាត្រា ១ ៖ ប្រទេសកម្ពុជាមាននាមជាផ្លូវការថា ˝រដ្ឋកម្ពុជា˝។

មាត្រា ១១ ៖ សេដ្ឋកិច្ចជាតិស្ថិតក្រោមការដឹកនាំរបស់រដ្ឋ។ រដ្ឋលើកស្ទួយជីវភាពប្រជាជនឱ្យមានកម្រិតខ្ពស់ជាលំដាប់លើគ្រប់ផ្នែក ដើម្បីកសាងប្រទេសជាតិ។

មាត្រា ១២ ៖ សេដ្ឋកិច្ចជាតិមានប្រាំ : សេដ្ឋកិច្ចរដ្ឋ, សេដ្ឋកិច្ចរដ្ឋចម្រុះនិងឯកជន, សេដ្ឋកិច្ចសមូហភាព, សេដ្ឋកិច្ចគ្រួសារ, និង សេដ្ឋកិច្ចឯកជន។

រដ្ឋគ្រប់គ្រងសហគ្រាសរដ្ឋយ៉ាងជិតដិត គឺដើម្បីពង្រីកតួនាទីសំខាន់នៃផ្នែកសេដ្ឋកិច្ចរដ្ឋចម្រុះនិងឯកជនក្នុងសេដ្ឋកិច្ចជាតិ ហើយទន្ទឹមនឹងនោះជួយទំនុកបម្រុងនិងណែនាំយ៉ាងសកម្មនូវការកសាងសេដ្ឋកិច្ចសមូហភាព សេដ្ឋកិច្ចគ្រួសារ និង សេដ្ឋកិច្ចឯកជន ឱ្យរីកចម្រើនតាមទិសដៅដែលមានប្រយោជន៍ដល់រដ្ឋ និងជីវភាពប្រជាជន។

មាត្រា១៣ ៖ រដ្ឋយកចិត្តទុកដាក់ពង្រីកផលិកម្មឧស្សាហកម្ម ដែលបម្រើកសិកម្ម ពង្រីកផលិតផលដែលប្រើប្រាស់ពង្រីកពាណិជ្ជកម្ម គមនាគមន៍ និង ដឹកជញ្ជូន។ រដ្ឋជួយទំនុកបម្រុង និង ពង្រីកសិប្បកម្ម និង ឧស្សាហកម្ម។

មាត្រា១៤ ៖ ទ្រព្យសម្បត្តិជាកម្មសិទ្ធិរបស់រដ្ឋ មាន ដីធ្លី ព្រៃឈើ សមុទ្រ ទន្លេ បឹង ធនធានធម្មជាតិ មជ្ឈមណ្ឌលសេដ្ឋកិច្ច វប្បធម៌ មូលដ្ឋានការពារប្រទេសនិងសំណង់ផ្សេងៗទៀតរបស់រដ្ឋ។

មាត្រា១៩ ៖ ពាណិជ្ជកម្មក្រៅប្រទេស ស្ថិតនៅក្រោមការគ្រប់គ្រងផ្តាច់មុខរបស់រដ្ឋ។

នាថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៨៩ នាសម័យប្រជុំវិសាមញ្ញនីតិកាលទី១នៃរដ្ឋសភារបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា គេបានធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ និង បានអនុម័តប្តូរ ˝សាធាណរដ្ឋប្រជាមានិតកម្ពុជា˝ ទៅជា ˝រដ្ឋកម្ពុជា˝ ហើយធ្វើកំណែទម្រង់សេដ្ឋកិច្ចពីសមាសភាពបី(សេដ្ឋកិច្ចរដ្ឋ សមូហភាព និង គ្រួសារ)ទៅសមាសភាពប្រាំ(សេដ្ឋកិច្ចរដ្ឋ សេដ្ឋកិច្ចរដ្ឋចម្រុះនិងឯកជន សេដ្ឋកិច្ចសមូហភាព សេដ្ឋកិច្ចគ្រួសារ និង សេដ្ឋកិច្ចឯកជន)។

៦- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាទី២(ពីឆ្នាំ១៩៩៣)

មាត្រា១ ៖ ប្រទេសកម្ពុជា ជាព្រះរាជាណាចក្រដែលព្រះមហាក្សត្រទ្រង់ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និង តាមលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។

មាត្រា៥១ ៖ -ថ្មី ព្រះរាជាណាចក្រកម្ពុជាអនុវត្តនយោបាយប្រជាធិបតេយ្យ សេរីពហុបក្ស។

មាត្រា៥៦ ៖ ព្រះរាជាណាចក្រកម្ពុជាអនុវត្តប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ។

មាត្រា៦០៖ពលរដ្ឋមានសិទ្ធិលក់ដូរផលិតផលរបស់ខ្លួនដោយសេរី។ ការតម្រូវឱ្យលក់ផលិតផលជូនរដ្ឋ ឬ ការយកភោគផល ឬ ទ្រព្យសម្បត្តិឯកជនទៅប្រើប្រាស់ ទោះបីមួយរយៈពេលក៏ដោយត្រូវហាមឃាត់ វៀរលែងតែក្នុងករណីពិសេសដែលមានច្បាប់អនុញ្ញាត។

មាត្រា៦២៖ រដ្ឋយកចិត្តទុកដាក់ជួយដោះស្រាយមធ្យោបាយផលិត ការពារថ្លៃផលិតផលជូនកសិករ សិប្បករ និង ជួយរកទីផ្សារលក់ផលិតផល។

មាត្រា៦៣៖ រដ្ឋយកចិត្តទុកដាក់គ្រប់គ្រងទីផ្សារជួយឱ្យជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមានកម្រិតសមរម្យ។

ចាប់តាំងពីថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣មក រដ្ឋធម្មនុញ្ញថ្មីត្រូវបានប្រកាសឱ្យប្រើប្រាស់ជាផ្លូវការជំនួសរដ្ឋធម្មនុញ្ញដែលត្រូវបានធ្វើវិសោធនកម្ម ក្នុងឆ្នាំ១៩៨៩ ហើយប្រទេសកម្ពុជាត្រូវបានគេហៅថា "ព្រះរាជាណាចក្រកម្ពុជា"។

## សន្និដ្ឋាន

កម្ពុជាគឺជាប្រទេសមួយដែលត្រឹមរយៈពេល៥០ឆ្នាំប៉ុណ្ណោះ ត្រូវបានផ្លាស់ប្តូរចំនួនប្រាំដងជាបន្តបន្ទាប់ នូវរដ្ឋធម្មនុញ្ញ ឈ្មោះប្រទេស ទង់ជាតិ ភ្លេងជាតិ របៀបរបបគ្រប់គ្រងរដ្ឋ នយោបាយ សេដ្ឋកិច្ច សង្គម និងទាំងផ្នត់គំនិតដល់ឫសគល់។ ការផ្លាស់ប្តូរទាំងអស់នេះ មិនបានធ្វើឱ្យប្រទេសនេះមានវឌ្ឍនភាពដូចបណ្តាប្រទេសជឿនលឿនដទៃទៀតឡើយ ផ្ទុយទៅវិញធ្វើឱ្យប្រទេសជាតិស្ទើរតែធ្លាក់ក្នុងក្តីអន្តរាយ បាត់បង់កិត្តិយស និងកិត្យានុភាពដែលធ្លាប់មានក្នុងសម័យមហានគរ។

ដើម្បីស្តារប្រទេសជាតិឱ្យមានភាពរីកចម្រើន ជាចំបងគឺត្រូវការជាចាំបាច់នូវស្ថិរភាពនយោបាយនិងការឯកភាពជាតិជាធ្លុងមួយ រួមគ្នា ការពារ កសាង ជំរុញ និងលើកកម្ពស់កិត្យានុភាពជាតិមាតុភូមិទាំងអស់គ្នា៕

## ឯកសារយោង


១. រដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជាឆ្នាំ១៩៤៧, ឆ្នាំ១៩៧២, ឆ្នាំ១៩៧៦, ឆ្នាំ១៩៨១, ឆ្នាំ១៩៨៩ និង ឆ្នាំ១៩៩៣

២. ឆេង វណ្ណារិទ្ធ "សេដ្ឋកិច្ចអន្តរកាល: បទពិសោធន៍ប្រទេសមួយចំនួន", ភ្នំពេញ, រាជបណ្ឌិត្យសភាកម្ពុជា, ខែសីហា ឆ្នាំ២០១៥

៣. ហ៊ុន សែន ៖ ១០ឆ្នាំនៃដំណើរកម្ពុជា ១៩៧៩-១៩៨៩"

៤. ឡុង សៀម "ប្រវត្តិសាស្ត្រសង្ខេបនៃប្រទេសកម្ពុជា", បណ្ឌិតសភាវិទ្យាសាស្ត្រ ស.ស.ស. ស. វិទ្យាស្ថាននៃបូព៌ាសាស្ត្រ, មូស្គូ, ១៩៨២

៥. International Monetary Fund World Economic Outlook(October-2018), Date 20 Mar 2019.


ᨀᨀ✵ᨀᨀ